

# ការងារអភិវឌ្ឍន៍ ប្រកបដោយច្នៃប្រឌិត និងចីរភាព

*ការជួញដូរមនុស្ស គឺជាបញ្ហាសកលដែលកំពុងកើតឡើងនៅគ្រប់ទីកន្លែងជុំវិញពិភពលោក ជាពិសេសនៅតំបន់អាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍។ តំបន់ទាំងនេះ ត្រូវបានចាត់ទុកថាជាតំបន់ស្នូលសម្រាប់ការជួញដូរមនុស្ស។ នៅតំបន់អាស៊ីខាងត្បូង ត្រូវបានគេរកឃើញថាជនរងគ្រោះចំនួន ៨៥ភាគរយ ក្នុងចំណោមជនរងគ្រោះទាំងអស់ជាជនរងគ្រោះដោយការជួញដូរកម្លាំងពលកម្មដោយបង្ខំ ហើយនៅក្នុងចំណោមជនរងគ្រោះទាំងអស់នោះផងដែរ ៤០ភាគរយ គឺជាកុមារ។ គំនិតផ្តួចផ្តើមក្នុងការទប់ស្កាត់ការជួញដូរមនុស្សនៅក្នុងមូលដ្ឋាន គឺផ្តោតទៅលើការលើកកម្ពស់ឲ្យមានការយល់ដឹងអំពីការទប់ស្កាត់ការជួញដូរមនុស្សជាចម្បង ជាជាងទៅលើមូលហេតុឫសគល់ដែលនាំឲ្យមានការជួញដូរមនុស្ស។ ហេតុដូច្នេះ ពិតជាមានការចាំបាច់ណាស់ក្នុងការរៀនសូត្រ និងវិភាគអំពីទស្សនវិស័យក្នុងការយល់ដឹងអំពីការជួញដូរមនុស្សនៅថ្នាក់មូលដ្ឋាន ដើម្បីធ្វើការដោះស្រាយបុព្វហេតុឫសគល់ដែលនាំឲ្យមានការជួញដូរមនុស្ស។*

នៅដើមឆ្នាំ២០១៨ អង្គការអាយស៊ីស៊ី និងអង្គការអភិវឌ្ឍន៍ដទៃទៀតមកពីប្រទេសនេប៉ាល់ ឥណ្ឌា បង់ក្លាដែស និងថៃ បានចូលរួមសហការគ្នាជាមួយនឹងអង្គការអ៊ីនធីអាក(Interact) ដើម្បីធ្វើការសិក្សារួមមួយស្តីពី "បទពិសោធន៍ និងការយល់ដឹងនៅថ្នាក់មូលដ្ឋាន ស្តីអំពីការជួញដូរមនុស្សនៅ អាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍" ហើយបានរំលេចចេញជារបាយការណ៍មួយដែលមានចំណងជើងថា "លើសពីការយល់ដឹង៖ ការរៀនសូត្រពីបទពិសោធន៍ ថ្នាក់មូលដ្ឋាន ដើម្បីបន្តក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស"។

ការរកឃើញដែលបានមកពីការសិក្សានេះ បានបង្ហាញឲ្យឃើញថា មូលហេតុដែលនាំឲ្យមានការជួញដូរមនុស្សគឺត្រូវបានផ្សារភ្ជាប់ជាមួយនឹងភាពក្រីក្រ ការខ្វះចំណេះដឹង សម្ភារៈនិយម និងសេចក្តីប្រាថ្នាខ្ពស់ បូករួមជាមួយនឹងគោលនយោបាយ និងការអនុវត្តច្បាប់នៅមានកម្រិត។ ភាពក្រីក្រ គឺជាកត្តាមួយដែលបានលើកឡើងជាញឹកញាប់បំផុតពីសំណាក់អ្នកឆ្លើយតបភាគច្រើន នៅតាមទីតាំងសិក្សានីមួយៗ។ ការរកឃើញនេះ ក៏បាន ឆ្លុះបញ្ចាំងពីភាពងាយរងគ្រោះខ្ពស់ និងហានិភ័យលើកុមារ និងយុវជនក្លាយជាជនរងគ្រោះនៃការជួញដូរមនុស្ស ឧទាហរណ៍ដូចជា ត្រូវបានគេបោកបញ្ឆោត និងធ្វើអាជីវកម្មលើពលកម្មកុមារ ការចាប់ជំរិត ការចាប់បង្ខំឲ្យសុំទាន និងការជួញដូរសរីរាង្គ។ លើសពីនេះទៀត ការរកឃើញនេះបានបង្ហាញឲ្យឃើញថា មានឪពុកម្តាយមួយចំនួនបានយកកូនខ្លួនឯងទៅប្រទេសជិតខាងដូចជាប្រទេសវៀតណាម ឲ្យសុំទាន ដោយសារតែភាពក្រីក្រ និងរកលុយបានលឿន។ ផ្អែកតាមការសិក្សានេះផងដែរ យុទ្ធសាស្ត្រដែលមានស្រាប់នៅថ្នាក់មូលដ្ឋាន គឺមានដូចជាការការពារខ្លួនឯងនៅក្នុងគ្រួសារ និងសហគមន៍ ការធ្វើអន្តរាគមន៍ពីអាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាល និងការផ្តោចសំខាន់ លើការផ្សព្វផ្សាយព័ត៌មាន និងការបង្កើនការយល់ដឹង។

ទិន្នន័យដែលប្រមូលបានពីតំបន់គោលដៅរបស់អង្គការអាយស៊ីស៊ីនៅខេត្តស្វាយរៀង គឺមានលក្ខណៈពិសេសជាងគេដោយសារតែអាជ្ញាធរមូលដ្ឋាន ក្រុមប្រឹក្សាឃុំ គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ) គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំសង្កាត់ (គ.ក.ន.ក) និងអ្នកដឹកនាំក្រុមជំនុំ បាននិងកំពុងធ្វើការសហការគ្នាយ៉ាងសកម្មក្នុងការផ្សព្វផ្សាយព័ត៌មាន និងរាយការណ៍អំពីករណីជួញដូរមនុស្ស។ ជាលទ្ធផលអ្នកឆ្លើយតបបានមានលើកឡើងថា "ការជួញដូរមនុស្សមានចំនួនច្រើននៅក្នុងទសវត្សឆ្នាំ២០០០ ប៉ុន្តែឥឡូវនេះការជួញដូរមនុស្សគឺមានចំនួនតិចជាងមុនឆ្ងាយណាស់ ដោយសារតែមានការពង្រឹងច្បាប់ និងការបង្កើនការយល់ដឹង។" ទោះជាយ៉ាងណាក៏ដោយ អ្នកឆ្លើយតបមួយចំនួនទៀតជឿថា ការពង្រឹងច្បាប់គឺអាចនៅមានការកែលំអបន្ថែមទៀត។

អាយស៊ីស៊ី គឺធ្វើការពាក់ព័ន្ធដោយផ្ទាល់នៅក្នុងការទប់ស្កាត់ការជួញដូរមនុស្សតាមរយៈគម្រោងមួយដែលមានឈ្មោះថា "ការទប់ស្កាត់ការជួញដូរមនុស្ស"។ គម្រោងផ្សេងៗទៀតរបស់អាយស៊ីស៊ី ដែលមានដូចជាគម្រោងសម្លេងកុមារ (វីអ៊ូធីស៊ី) និងគម្រោងការអភិវឌ្ឍន៍គ្រួសារ និងសាលារៀន (ហ្វាស) បានធ្វើការចូលរួមចំណែកក្នុងការទប់ស្កាត់ការជួញដូរមនុស្សនៅតាមតំបន់គោលដៅ។ អាយស៊ីស៊ី មិនត្រឹមតែផ្តល់ព័ត៌មាន និងការយល់ដឹង អំពីបញ្ហាកើតឡើងនៃការជួញដូរមនុស្សតែប៉ុណ្ណោះទេ លើសពីនេះទៀត អាយស៊ីស៊ីក៏ធ្វើការដោយផ្ទាល់ជាមួយអ្នកមានសិទ្ធិ និងអ្នកធានាឲ្យមានសិទ្ធិផងដែរ។ នេះគឺត្រូវបានធ្វើឡើងយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរមូលដ្ឋាន អង្គការនៅតាមសហគមន៍ និងជាមួយកុមារ យុវជន និងមនុស្សពេញវ័យ។ អាយស៊ីស៊ី នឹងប្រើប្រាស់របាយការណ៍ស្រាវជ្រាវមួយនេះពីអង្គការអ៊ីនធីអាក ដើម្បីលើកកម្ពស់ឲ្យមានការចូលរួម និងសកម្មភាពរបស់អាយស៊ីស៊ី ក្នុងការប្រយុទ្ធប្រឆាំង នឹងការជួញដូរមនុស្សនៅកម្ពុជា។

កាលបរិច្ឆេទ ៖ មិថុនា ២០១៨